U.S. Small Business Administration

# មូលនិធិស្តារនីយកម្មភោជនីយដ្ឋាន

ច្បាប់ផែនការជួយសង្គ្រោះអាមេរិកបានបង្កើតឡើងនូវមូលនិធិស្តារនីយកម្មភោជនីយដ្ឋាន (RRF) ដើម្បីផ្តល់ថវិកាជួយភោជនីយដ្ឋាន និងអាជីវកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផ្សេងទៀត ដើម្បីបន្តបើកដំណើរការ។
កម្មវិធីនេះផ្តល់ឱ្យភោជនីយដ្ឋាននូវថវិកាស្មើនឹងចំនួនប្រាក់ខាតបង់នៃប្រាក់ចំណូលដែលទាក់ទងនឹងជំងឺរាតត្បាតរហូតដល់ 10 លានដុល្លារសម្រាប់អាជីវកម្មមួយ និងមិនលើសពី 5 លានដុល្លារសម្រាប់ទីតាំងជាក់ស្តែងមួយ។ អ្នកទទួលមិនតម្រូវឱ្យសងប្រាក់វិញទេ ដរាបណាមូលនិធិត្រូវបានប្រើសម្រាប់ការប្រើប្រាស់ដែលមានលក្ខណៈត្រឹមត្រូវមិនលើសពីថ្ងៃទី 11 ខែមីនាឆ្នាំ 2023 ។

ចូលទៅកាន់ www.sba.gov/resthead សម្រាប់ព័ត៌មានបន្ថែម។

## អ្នកណាខ្លះអាចដាក់ពាក្យបាន

អង្គភាពមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលធ្លាប់ខាតបង់ប្រាក់ចំណូលទាក់ទងនឹងជំងឺរាតត្បាតរួមមាន៖

- ភោជនីយដ្ឋាន
- ហាងម្ហូបអាហារ ឡានដឹកម្ហូបអាហារ រទេះម្ហូបអាហារ
- ក្រុមហ៊ុនផ្គត់ផ្គង់ម្ហូបអាហារ
- បារនីយដ្ឋាន សាឡុន ហាងអាហារ តៀមស្រា
- បារនីយដ្ឋានសម្រាប់អាហារសម្រន់ និងភេសជ្ជៈមិនមែនគ្រឿងស្រវឹង
- កន្លែងដែលមានអាជ្ញាបណ្ណ ឬទីតាំងផលិតភេសជ្ជៈជាគ្រឿងស្រវឹងដែលសាធារណជនអាចភ្លក្សរសជាតិ យកជាគំរូ ឬទិញផលិតផល
- ហាងនំ*
- កន្លែងលក់ស្រាបៀរ កន្លែងភ្លក្សស្រា កន្លែងលក់ស្រា*
- រោងចក្រផលិតស្រាបៀរ និង/ឬរោងចក្រផលិតស្រាបៀរខ្នាតតូច*
- កន្លែងផលិតស្រា និងចម្រាញ់ស្រា*
- សណ្ឋាគារ*

* ប្រសិនបើការលក់នៅនឹងកន្លែងដល់សាធារណៈជនរួមមានយ៉ាងហោចណាស់ 33 ភាគរយនៃវិក្កយបត្រសរុប

## របៀប និងពេលណាដែលត្រូវដាក់ពាក្យ

អ្នកអាចដាក់ពាក្យសុំតាមរយៈដៃគូភោជនីយដ្ឋាននៅកន្លែងលក់ដែលទទួលស្គាល់ដោយ SBA ឬដោយផ្ទាល់តាមរយៈ SBA ក្នុងវិបផតថលដាក់ពាក្យសុំតាមអ៊ីនធឺណិតដែលនឹងមាននៅលើ https://restaurants.sba.gov។

SBA នឹងប្រកាសនៅពេលពាក្យសុំបើកដំណើរការតាមអ៊ីមែល និងតាមប្រព័ន្ធផ្សព្វផ្សាយសង្គម។
អ្នកអាចជាវការជូនដំណឹងតាមអ៊ីមែលរបស់យើងតាមរយៈ www.sba.gov/updates ឬស្វែងរកគណនីប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់យើងតាមរយៈ www.sba.gov/social-media។

ឯកសារបន្ថែមអាចនឹងត្រូវបានស្នើសុំនៅពេលអ្នកដាក់ពាក្យ។ មើលបញ្ជីពេញនៅ www.sba.gov/restaurants ។

## រកជំនួយសម្រាប់ពាក្យសុំរបស់អ្នក

សម្រាប់ជំនួយក្នុងការរៀបចំពាក្យសុំរបស់អ្នក អ្នកអាចទទួលបានដូចតទៅ៖

- ជំនួយពីមជ្ឈមណ្ឌលផ្តល់ព័ត៌មាន៖ 1-844-279-8898 (ម៉ោង៖ ថ្ងៃចន្ទដល់ ថ្ងៃសុក្រម៉ោង 8 ព្រឹក ដល់ 8 យប់ ម៉ោងភាគខាងកើត,ET)
- ការិយាល័យមណ្ឌល SBA ក្នុងតំបន់របស់អ្នកនៅ www.sba.gov/local-assistance
- សំណុំបែបបទពាក្យសុំគំរូ និងមគ្គុទេសក៍កម្មវិធីលម្អិតអាចរកបានជាច្រើនភាសានៅ www.sba.gov/restaurants ។